# សំណៅជ្រើសរើសរបស់អ្នកដាក់ពាក្យសុំនៃកម្មវិធីជួយឱ្យធ្វើការ និងទទួលខុសត្រូវចំពោះកូននៃរដ្ឋកាលីហ្វ័រនីញ៉ា (CalWORKs) ប្រាក់ផ្ដល់ឱ្យសំរាប់សេចក្ដីត្រូវការជាបន្ទាន់/ប្រាក់ជំនួយដោយរហ័ស

ឈ្មោះសំណុំរឿង :

លេខសំណុំរឿង :

លេខ/ឈ្មោះអ្នកកាន់សំណុំរឿង :

ដោយសារតែសេចក្ដីត្រូវការជាបន្ទាន់របស់លោកអ្នក គឺជាការបណ្ដេញចេញពីផ្ទះសម្បែង ហើយដោយលោកអ្នកពុំមានប្រាក់ចំណូលនិងធនធានគ្រប់គ្រាន់ សំរាប់បង់ថ្លៃឈ្នួលផ្ទះ លោកអ្នកអាចជ្រើសរើសអំពីរបៀបទទួលប្រាក់ជំនួយ ។

លោកអ្នកត្រូវតែមានលក្ខខណ្ឌដូចនៅខាងក្រោមនេះ នៅមុនពេលប្រាក់ជំនួយអាចត្រូវបានផ្ដល់ឱ្យលោកអ្នក :

- លោកអ្នកត្រូវតែមានសេចក្ដីប្រកាសបណ្ដេញចេញពីទីលំនៅ ។ លិខិតនេះអាចជាលិខិតឱ្យបង់នៅក្នុងរវាង៣ថ្ងៃ ឬត្រូវឈប់នៅ ។
- លោកអ្នកត្រូវតែគ្មានប្រាក់គ្រប់គ្រាន់ដើម្បីបង់ថ្លៃឈ្នួលផ្ទះដែលលោកអ្នកបានជំពាក់ ។
- នៅក្នុងពេលបច្ចុប្បន្ននេះ លោកអ្នកត្រូវតែនៅក្នុងផ្ទះ ។

លោកអ្នកមានការជ្រើសរើសពីរយ៉ាង ។ សូមអានពត៌មាននៅខាងក្រោមជាមុនសិននៅមុនពេលដែលលោកអ្នកធ្វើការជ្រើសរើស ។ បើសិនជាលោកអ្នកមានសំណួរ សូមសួរអ្នកកាន់សំណុំរឿងរបស់លោកអ្នក ។

## ប្រាក់ផ្ដល់ឱ្យសំរាប់សេចក្ដីត្រូវការជាបន្ទាន់

បើសិនជាលោកអ្នកជ្រើសរើសយកប្រាក់ផ្ដល់ឱ្យសំរាប់សេចក្ដីត្រូវការជាបន្ទាន់ (Immediate Need payment) លោកអ្នកអាចទទួលប្រាក់នេះនៅក្នុងរវាង១ថ្ងៃធ្វើការ បន្ទាប់ពីពេលដែលលោកអ្នកបានដាក់សុំមក ។ លោកអ្នកអាចទទួលចំនួនដែលលោកអ្នកមានសិទ្ធិទទួលឬក៏ចំនួន២០០ដុល្លារផ្ដល់ឱ្យចំនួនណាដែលតិចជាង ។

បន្ទាប់ពីពេលលោកអ្នកបានទទួលប្រាក់បង់ឱ្យសំរាប់សេចក្ដីត្រូវការជាបន្ទាន់នោះមក ខណ្ឌត្រូវតែសំរេចថាតើលោកអ្នកអាចទទួលទទួលប្រាក់ជំនួយឬទេ នៅក្នុងរវាង១៥ថ្ងៃធ្វើការ ។

ខណ្ឌនឹងជំរាបលោកអ្នកបានឱ្យដឹងអំពីភស្តុតាងអ្វីខ្លះដែលលោកអ្នកត្រូវការបង្ហាញ ។ លោកអ្នកត្រូវតែផ្ដល់ភស្តុតាងនៃពត៌មានទាំងអស់ដែលខណ្ឌបានសួររក នៅក្នុងរវាង១៥ថ្ងៃធ្វើការ ។

បន្ទាប់មក បើខណ្ឌធ្វើការបញ្ជាក់ថា លោកអ្នកមានសិទ្ធិទទួលនៅក្នុងរវាង១៥ថ្ងៃធ្វើការ ខណ្ឌនឹងផ្ដល់ប្រាក់ជំនួយនៅសល់ដែលនៅជំពាក់នោះដល់លោកអ្នក ។

## ការកំណត់ក្នុងការផ្ដល់ប្រាក់ជំនួយដោយរហ័ស

បើសិនជាលោកអ្នកជ្រើសរើសយកប្រាក់ជំនួយដោយរហ័ស (Expedited Grant) លោកអ្នកអាចទទួលប្រាក់នេះនៅក្នុងរវាង៣ថ្ងៃធ្វើការ បន្ទាប់ពីពេលដែលលោកអ្នកបានដាក់សុំមក ។ នេះគឺមានន័យថា លោកអ្នកប្រហែលជាអាចទទួលប្រាក់ជំនួយទាំងអស់ដែលលោកអ្នកមានសិទ្ធិទទួល ទោះបីជាវាមានចំនួនច្រើនជាង២០០ដុល្លារក៏ដោយ ។

ខណ្ឌត្រូវតែសំរេចថាតើលោកអ្នកអាចទទួលទទួលប្រាក់ជំនួយឬទេ នៅក្នុងរវាង៣ថ្ងៃធ្វើការ ។

ខណ្ឌនឹងជំរាបឱ្យលោកអ្នកបានដឹង ថាតើភស្តុតាងអ្វីខ្លះដែលលោកអ្នកត្រូវយកមកបង្ហាញ ។ លោកអ្នកត្រូវតែផ្ដល់ភស្តុតាងដែលខណ្ឌបានសួររក នៅក្នុងរវាងបីថ្ងៃធ្វើការ ។

នៅក្នុងថ្ងៃធ្វើការទី៣ លោកអ្នកនឹងបានទទួលប្រាក់ជំនួយផ្ដល់ឱ្យពេញដោយផ្អែកទៅលើការកំណត់ក្នុងការផ្ដល់ប្រាក់ជំនួយដោយរហ័ស ឬក៏ប្រាក់បង់ឱ្យសំរាប់សេចក្ដីត្រូវការជាបន្ទាន់(រហូតដល់ទៅ២០០ដុល្លារ) ។

សូមប្រាប់យើង ថាតើលោកអ្នកត្រូវការ ប្រាក់បង់ឱ្យសំរាប់សេចក្ដីត្រូវការជាបន្ទាន់ ឬក៏ការកំណត់ក្នុងការផ្ដល់ប្រាក់ជំនួយដោយរហ័ស ។ សូមគូស(✓) នៅខាងក្រោម ។

☐ ខ្ញុំចង់បាន**ប្រាក់ផ្ដល់ឱ្យសំរាប់សេចក្ដីត្រូវការជាបន្ទាន់**

☐ ខ្ញុំចង់បានប្រាក់បង់ឱ្យតាម**ការកំណត់ក្នុងការផ្ដល់ប្រាក់ជំនួយដោយរហ័ស**

## សេចក្ដីបញ្ជាក់ដោយលិខិត

ខ្ញុំបានអានពត៌មាននៅខាងលើ និងយល់ថានៅពេលណាដែលខ្ញុំអាចទទួលប្រាក់ផ្ដល់ឱ្យសំរាប់សេចក្ដីត្រូវការជាបន្ទាន់ ឬប្រាក់បង់ឱ្យតាមការកំណត់ក្នុងការផ្ដល់ប្រាក់ជំនួយដោយរហ័ស ។

| ហត្ថលេខា | កាលបរិច្ឆេទ |
|---|---|
| | |

ការពន្យល់ :